ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៩/២១ - ខេមបូ ហៃនសាំ អិលធីឌី

កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ុក រី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេមបូ ហៃនសាំ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦១៨ ៨១៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

១- លោក ស ប៊ុនធឿន រដ្ឋបាល

២- លោក វេន យីហេង រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ខេមបូ ហៃនសាំ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨១ ៨៨ ៧៧ ០១ / ០៩៦ ៧៦ ៧៥ ១៤៤ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

១- លោកស្រី ម៉ន ចន្ទា អនុប្រធានសហព័ន្ធសហជីពកម្ពុជា

២- លោកស្រី ៣ញ គឿន មន្ត្រីសហព័ន្ធសហជីពកម្ពុជា

៣- លោក វ៉ាន់ បូរ៉ា ប្រធានសហជីពមូលដ្ឋាន

៤-លោកស្រី ទៀង ស្រស់ អនុប្រធានសហជីពមូលដ្ឋាន

៥- លោកស្រី សឿ មុំ លេខាធិការសហជីពមូលដ្ឋាន

៦- លោកស្រី យោន ម៉ុម កម្មករនិយោជិត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបើកកន្លែងដើម្បីឱ្យកម្មករប្រើប្រាស់ក្នុងពេលបំពេញការងារឱ្យក្រុមហ៊ុន។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនបើកជូនទេ។

២- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនប្តូរធុងទឹកក្តៅ ទឹកត្រជាក់នៅអគារA និងអគារB ដោយកន្លងមកក្រុមហ៊ុនបានជួសជុលដែរ ប៉ុន្តែនៅតែប្រើមិនបាន។ ដោយឡែក ភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុននឹងជួសជុលសារជាថ្មី តែមិនមានការប្តូរថ្មីទេ។

៣- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនរាល់ការប្តូរថ្ងៃបុណ្យត្រូវមានការឯកភាពពីកម្មករ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ដែលធ្លាប់អនុវត្តកន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូក ទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី ១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជា នឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃ ក្រុមហ៊ុន ខេមបូ ហ៊ៃនសាំ អិលធីឌី លេខ ២៤៣ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេមបូ ហ៊ៃនសាំ អិលធីឌី ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ស្តីពីការទាមទារឱ្យក្រុមហ៊ុន

THE ARBITRATION COUNCIL

ដោះស្រាយលក្ខខណ្ឌការងារចំនួន ៧ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២១ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៤ចំណុច លើការទាមទារចំនួន ៧ចំណុច។ ចំណុចមិនសះជាដែលនៅសល់ចំនួន ៣ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ ២៤៣ ក.ប/អក/វក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានសំណើសុំពន្យារនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ០០៩/២១នេះ ពីភាគីកម្មករនិយោជិត ដោយសារមានការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងមានការឯកភាពដោយភាគីនិយោជក តាមរយៈលិខិតចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១។ រហូតដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានសំណើរបស់ភាគីកម្មករនិយោជិតស្នើសុំបន្តនីតិវិធីអាជ្ញាកណ្តាល តាមរយៈលិខិតចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១។ ដូចនេះ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៣ចំណុចនេះ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង ០០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដើម្បីគោរពតាមវិធានការសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេស ដើម្បីរក្សាគម្លាតសុវត្ថិភាព ក្រុមអាជ្ញាកណ្តាលបានធ្វើសវនាការអនឡាញ ដោយប្រើប្រព័ន្ធហ្សូម (zoom) ដោយបានបែកបន្ទប់រវាងភាគីនៃវិវាទ និងក្រុមអាជ្ញាកណ្តាល។ ភាគីទាំងពីរមិនជំទាស់ចំពោះនីតិវិធី និងមធ្យោបាយធ្វើសវនាការរបស់ក្រុមអាជ្ញាកណ្តាលនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាចំនួន ២ចំណុច គឺចំណុចវិវាទទី១ និងចំណុចវិវាទទី២។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុចប៉ុណ្ណោះ គឺចំណុចវិវាទទី៣។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងភស្តុតាង និងថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ និងភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន ៖**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតចុះថ្ងៃអង្គារ ២កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់តំណាងភាគីនិយោជក និងតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំព្យួរនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល សំណុំរឿង ០០៩/២១ ខេមបូ ហ៊ែនសាំ អិលធីឌី។

២- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ របស់លោក CHOI KWANG YEOL ជានាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក ស ប៊ុនធឿន ជាប្រធានផ្នែករដ្ឋបាល ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះបញ្ជិកាលេខ ០០៤ កប/អក/អធក ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៤- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ PTL-២០២១០៦០៤៤៧ អពដ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ MOC ៨២២៨៦២០៤ ពណ.ចបព ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦។

៦- លក្ខន្តិកៈក្រុមហ៊ុន ហឺរ៉ាយហ្សិន អៅជរ (ខេមបូឌា) បានតម្កល់ទុកលេខ ០៧៨០១០៦ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៧- វិញ្ញាបនបត្របញ្ជាក់ពីភាពជាតំណាងបំផុតរបស់សហជីពអភិវឌ្ឍន៍ចលនាការងារកម្ពុជា នៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ ២៥៤/២០ ក.ប/វ.ប.វ.ក ចុះថ្ងៃសុក្រ ៨កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០។

៨- លិខិតចុះថ្ងៃសុក្រ ១៣រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមក អគ្គនាយិកាក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក អាណត្តិទី៨។

៩- កំណត់ហេតុស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកពេញសិទ្ធិ និងប្រតិភូបុគ្គលិកជំនួយ អាណត្តិទី៨ ប្រចាំរោងចក្រកាត់ដេរ ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០។

១០- កិច្ចព្រមព្រៀងរវាង រោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ជាមួយនិង សហជីព និងប្រតិភូបុគ្គលិក នៃរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការប្តូរថ្ងៃឈប់សម្រាក។

១១- កិច្ចព្រមព្រៀងរវាង រោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ជាមួយនិង សហជីព និងប្រតិភូបុគ្គលិក នៃរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការប្តូរថ្ងៃឈប់សម្រាក។

១២- កិច្ចព្រមព្រៀងរវាង រោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ជាមួយនិង សហជីព និងប្រតិភូបុគ្គលិក នៃរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការប្តូរថ្ងៃឈប់សម្រាក។

THE ARBITRATION COUNCIL

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតចុះថ្ងៃអង្គារ ២កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១ របស់តំណាងភាគីនិយោជក និងតំណាងភាគីកម្មកនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំព្យួរនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល សំណុំរឿង០០៩/២១ ខេមបូ ហ៊ែនសាំ អិលធីឌី។

២- លិខិតចុះថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងភាគីកម្មកនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃ ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំបើកសវនាការតាមនីតិវិធីក្នុង សំណុំរឿង០០៩/២១ ខេមបូ ហ៊ែនសាំ អិលធីឌី។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពកម្ពុជា នៃរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី លេខ ០៩៨/២០ ក.ប/វ.ប.វ.ក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០។

៤- លិខិតលេខ ២២៣ ក.ប/អក/វក ចុះថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមក ប្រធានសហជីពកម្ពុជា នៃរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិទី២។

៥- សារណាការពារ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់លោក វ៉ាន់ បូរ៉ា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារក្នុងសំណុំរឿង ០០៩/២១ ខេមបូ ហ៊ែនសាំ អិលធីឌី។

៦- លិខិតជំទាស់ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់លោក វ៉ាន់ បូរ៉ា គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជំទាស់ទៅនឹងឯកសារក្នុងសំណុំរឿង ០០៩/២១ ខេមបូ ហ៊ែនសាំ អិលធីឌី។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ ២៤៣ ក.ប/អក/វក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី លេខ ០៣១ កប/អក/វក/កវក៤ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ១៩២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ១៩៣ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី មានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ២០៧៣ នាក់។ *(យោងតាមរបាយការណ៍លេខ ២៤៣ ក.ប/អក/វក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី)*
- សហជីពកម្ពុជា នៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ លេខចុះបញ្ជី ១១២២០៨៥២ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ និងមានថ្នាក់ដឹកនាំសហជីពចំនួន ៣រូប គឺ ១. លោក វ៉ាន់ បូរ៉ា ជាប្រធាន, ២. លោកស្រី ទៀង ស្រស់ ជាអនុប្រធាន, និង ៣. លោកស្រី សឿ មុំ ជាលេខាធិការិនី។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០៣១កប/អក/វក/ក.វ.ក៤ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ដែលមានកម្មករនិយោជិតចំនួន ៣នាក់ រួមមាន ៖ ១. វ៉ាន់ បូរ៉ា, ២. សឿ មុំ, និង ៣. នេត តារា ។

**ចំណុចវិវាទទី៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករាល់ការប្តូរថ្ងៃបុណ្យ ត្រូវមានការឯកភាពពីកម្មករនិយោជិត**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជករាល់ការផ្លាស់ប្តូរថ្ងៃឈប់បុណ្យត្រូវមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ការអនុវត្តនៅក្នុងក្រុមហ៊ុន មុនពេលមានការផ្លាស់ប្តូរថ្ងៃឈប់បុណ្យទៅឈប់នៅថ្ងៃផ្សេង និយោជកបានធ្វើការប្រជុំពិភាក្សាជាមួយប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពប្រចាំក្រុមហ៊ុន ហើយសម្រេចទៅតាមមតិភាគច្រើននៃការប្រជុំចំពោះការផ្លាស់ប្តូរនោះ។
  - នៅក្នុងក្រុមហ៊ុនមានសហជីពទាំងអស់ចំនួន ៥ ក្នុងនោះមានសហជីពមានភាពជាតំណាងបំផុត ចំនួន ១ និងមានប្រតិភូបុគ្គលិកចំនួន ២១នាក់។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ចំពោះការផ្លាស់ប្តូរថ្ងៃឈប់បុណ្យ និយោជកត្រូវមានការស្ទង់មតិពីកម្មករនិយោជិតម្នាក់ៗ ដោយផ្អែកទៅតាមមតិភាគច្រើន។
  - កន្លងមក រាល់ការផ្លាស់ប្តូរការឈប់ថ្ងៃបុណ្យ និយោជកមិនមានការស្ទង់មតិ ឬពិភាក្សាជាមួយកម្មករនិយោជិតម្នាក់ៗ នោះទេ។
  - ការអនុវត្តរបស់និយោជកមិនត្រឹមត្រូវនោះទេ ពីព្រោះកម្មករនិយោជិតមិនបានឯកភាពក្នុងការផ្លាស់ប្តូរថ្ងៃឈប់បុណ្យតាមការស្នើសុំរបស់ប្រតិភូបុគ្គលិក ឬថ្នាក់ដឹកនាំសហជីពនោះទេ។

THE ARBITRATION COUNCIL

- កម្មករនិយោជិតបានតវ៉ាទៅនឹងការផ្លាស់ប្តូរថ្ងៃឈប់បុណ្យរបស់ក្រុមហ៊ុន ព្រោះសិទ្ធិឈប់សម្រាកថ្ងៃបុណ្យ គឺជាសិទ្ធិរបស់កម្មករនិយោជិតក្នុងការពិភាក្សាជាមួយនិយោជក។
- យោងតាមច្បាប់ស្តីពីការងារ ចំពោះការផ្លាស់ប្តូរការឈប់ថ្ងៃបុណ្យ គឺផ្អែកលើគោលការណ៍ស្ម័គ្រចិត្តរបស់កម្មករនិយោជិត។
- ក្រៅពីការផ្លាស់ប្តូរថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរ និងឈប់បុណ្យភ្ជុំបិណ្ឌ និយោជកក៏មានការផ្លាស់ប្តូរថ្ងៃឈប់បុណ្យផ្សេងៗផងដែរ។

- ភាគីនិយោជកបញ្ជាក់ថាមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបាន ដោយមូលហេតុថា ៖
  - និយោជកផ្លាស់ប្តូរថ្ងៃឈប់បុណ្យយោងទៅលើ ៖
    - ការប្រជុំពិភាក្សាជាមួយប្រតិភូបុគ្គលិក និងសហជីពប្រចាំក្រុមហ៊ុន ដែលអនុវត្តរយៈពេល ១៥ឆ្នាំ មកហើយ និងមិនដែលមានបញ្ហាអ្វីនោះទេ។
    - ការផ្លាស់ប្តូរថ្ងៃឈប់បុណ្យកើតឡើងដោយមានការស្នើសុំពីប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព បន្ទាប់មកនិយោជកហៅពួកគាត់ប្រជុំ និងធ្វើកិច្ចព្រមព្រៀងក្នុងការផ្លាស់ប្តូរថ្ងៃឈប់បុណ្យនោះ។ ចំពោះប្រតិភូបុគ្គលិក ឬថ្នាក់ដឹកនាំសហជីពដែលមានមតិភាគតិចមិនយល់ស្រប គឺនិយោជកអនុវត្តស្របទៅតាមសំឡេងភាគច្រើន។
    - ច្បាប់បានចែងឱ្យមានប្រតិភូបុគ្គលិកនៅក្នុងក្រុមហ៊ុន និងសហជីពដែលមានភាពជាតំណាងបំផុត ដែលមានសិទ្ធិតំណាងឱ្យកម្មករនិយោជិត ព្រោះកម្មករនិយោជិតបានប្រគល់សិទ្ធិឱ្យពួកគាត់រួចហើយ ហេតុនេះ ពួកគាត់មានសិទ្ធិក្នុងការសម្រេចជំនួសកម្មករនិយោជិត។
    - ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា និយោជកមានសិទ្ធិក្នុងការផ្លាស់ប្តូរថ្ងៃឈប់សម្រាកក្នុងស្ថានភាពចាំបាច់។
  - ចំពោះការផ្លាស់ប្តូរថ្ងៃឈប់បុណ្យដោយមានការស្ទង់មតិពីកម្មករនិយោជិតម្នាក់ៗ គឺធ្វើឱ្យខាតពេលវេលា ដែលធ្វើឱ្យស្ទះសង្វាក់ផលិតកម្មនៅក្នុងក្រុមហ៊ុន។
  - ជាទូទៅ ចំពោះការផ្លាស់ប្តូរថ្ងៃឈប់បុណ្យ គឺអនុវត្តចំពោះការឈប់សម្រាកបុណ្យចូលឆ្នាំខ្មែរ និងការឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។ ក្រៅពីការឈប់បុណ្យទាំងពីរនេះ គឺនិយោជកអនុវត្តការឈប់សម្រាកស្របតាមប្រតិទិនជាធម្មតា។

## ហេតុផលនៃសេចក្តីសម្រេច ៖

### ចំណុចវិវាទទី ៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជករាល់ការផ្លាស់ប្តូរថ្ងៃឈប់បុណ្យត្រូវមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនៅពេលនិយោជកធ្វើការផ្លាស់ប្តូរថ្ងៃឈប់បុណ្យទៅឈប់សម្រាកនៅថ្ងៃផ្សេងតម្រូវឱ្យមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ ដែរ ឬទេ?

កថាខណ្ឌទី១ មាត្រា ១៦១ នៃច្បាប់ស្តីពីការងារចែងថា ៖ *"រៀងរាល់ឆ្នាំក្រសួងទទួលបន្ទុកវិស័យការងារចេញប្រកាសកំណត់ថ្ងៃបុណ្យ ដែលត្រូវឈប់មានប្រាក់ឈ្នួល សំរាប់កម្មករនិយោជិតនៃសហគ្រាសទាំងអស់។"*

THE ARBITRATION COUNCIL

ប្រការ ១ នៃប្រកាសលេខ ១០ សកបយ. ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីប្រាក់បំណាច់នៃការងារដែលបានធ្វើការក្នុងឱកាសថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា ៖ *"ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតរបស់ខ្លួនបានឈប់សម្រាក ដោយមានប្រាក់ឈ្នួលក្នុងឱកាសថ្ងៃឈប់បុណ្យ ដែលកំណត់ជារៀងរាល់ឆ្នាំ ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។"*

ប្រការ ២ នៃប្រកាសលេខ ១០ សកបយ. ខាងលើដដែលចែងថា ៖ *"ក្នុងករណីចាំបាច់ដែលគ្រឹះស្ថាន ឬសហគ្រាស មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃបុណ្យ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស អាចសម្របសម្រួលជាមួយកម្មករនិយោជិតរបស់ខ្លួន ឱ្យធ្វើការនៅថ្ងៃឈប់បុណ្យទាំងនោះបាន។"*

ប្រការ ៣ នៃប្រកាសលេខ ១០ សកបយ. ខាងលើដដែលចែងថា ៖ *"ការធ្វើការថ្ងៃបុណ្យ ត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិត។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ៩៩/០៩-យីង ឡែន ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយ កថាខណ្ឌទី១ មាត្រា ១៦១ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ១០ សកបយ. ខាងលើថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតមានសិទ្ធិស្របច្បាប់នៅក្នុងការឈប់សម្រាកនៅថ្ងៃបុណ្យ។ តែទោះបីជាយ៉ាងនេះក៏ដោយ ភាគីនិយោជកអាចសម្របសម្រួលជាមួយកម្មករនិយោជិតបានក្នុងការតម្រូវឱ្យពួកគាត់មកធ្វើការនៅថ្ងៃបុណ្យ តែការធ្វើការថ្ងៃបុណ្យ ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តរបស់កម្មករនិយោជិត។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនខាងលើដែរ។

យោងតាមប្រកាសលេខ ១០ សកបយ. ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្នុងករណីដែលសហគ្រាសមិនអាចបញ្ឈប់សកម្មភាពការងារបានក្នុងឱកាសថ្ងៃឈប់បុណ្យ និយោជកអាចសម្របសម្រួលជាមួយកម្មករនិយោជិត និងត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិតផងដែរចំពោះការធ្វើការនៅថ្ងៃឈប់បុណ្យនោះ។ ក្នុងករណីនេះ ភាគីនិយោជកលើកឡើងថា និយោជកផ្លាស់ប្តូរថ្ងៃឈប់បុណ្យទៅឈប់នៅថ្ងៃផ្សេងវិញ គឺធ្វើឡើងដោយមានការស្នើសុំពីប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពទៅនិយោជក បន្ទាប់មកនិយោជកបានហៅថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិកមកប្រជុំពិភាក្សា ហើយសម្រេចតាមមតិភាគច្រើននៃការប្រជុំនោះ។ តែយ៉ាងណាមិញ ភាគីកម្មករនិយោជិតលើកឡើងថា ពួកគាត់មិនបានឯកភាពក្នុងការផ្លាស់ប្តូរថ្ងៃឈប់បុណ្យតាមការស្នើសុំរបស់ប្រតិភូបុគ្គលិក ឬថ្នាក់ដឹកនាំសហជីពនោះទេ ព្រោះការឈប់សម្រាកថ្ងៃបុណ្យ គឺជាសិទ្ធិរបស់កម្មករនិយោជិត។ ជាការកត់សម្គាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ត្រូវមានការឯកភាពពីកម្មករនិយោជិតជាមុនសិន មុននឹងធ្វើការស្នើសុំទៅនិយោជកអំពីការផ្លាស់ប្តូរថ្ងៃឈប់បុណ្យទៅថ្ងៃផ្សេង ពីព្រោះការឈប់ថ្ងៃបុណ្យ គឺជាសិទ្ធិរបស់កម្មករនិយោជិត។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជក គឺមិនទាន់ត្រឹមត្រូវស្របតាមប្រកាសលេខ ១០ សកបយ. ខាងលើនោះឡើយ ពោលគឺការធ្វើការថ្ងៃឈប់បុណ្យត្រូវឈរលើគោលការស្ម័គ្រចិត្តរបស់កម្មករនិយោជិត។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផ្លាស់ប្តូរថ្ងៃឈប់បុណ្យទៅឈប់សម្រាកនៅថ្ងៃផ្សេងត្រូវមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកអនុវត្តការផ្លាស់ប្តូរថ្ងៃឈប់បុណ្យត្រូវមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី ៣ ៖**

- បង្គាប់ឱ្យនិយោជកអនុវត្តការផ្លាស់ប្តូរថ្ងៃឈប់បុណ្យត្រូវមានការឯកភាពពីកម្មករនិយោជិតម្នាក់ៗ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះគូភាគីតែម្តង ដោយយោងតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ឡុន ស៊ីផាន់**

ហត្ថលេខា ៖ ----------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------

THE ARBITRATION COUNCIL